ASIAN DEVELOPMENT BANK
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel +63 2 632 4444
Fax +63 2 636 2444

www.adb.org

NEWS RELEASE

# ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ផ្លូវថ្នល់ដែលមានសុវត្ថិភាព ធន់នឹងអាកាសធាតុ ដល់តំបន់ជនបទក្រីក្ររបស់កម្ពុជា

**ម៉ានីល ហ្វីលីពីន (១១ សីហា ២០១៤)** - ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នឹងផ្តល់ហិរញ្ញប្បទានចំនួន ១១៨ លានដុល្លារអាមេរិក សម្រាប់គម្រោងកែលំអផ្លូវជនបទ ដែលនឹងតភ្ជាប់ខេត្តចំនួន ៩ របស់ប្រទេសកម្ពុជា ទៅនឹងទីផ្សារ និងសេវាកម្មសង្គមនានា ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាពចំណាយ។

លោក Shihiru Date អ្នកឯកទេសជាន់ខ្ពស់ផ្នែកគមនាគមន៍នៃ ADB និយាយថា "សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ពឹងផ្អែកកាន់តែខ្លាំងឡើងទៅលើបណ្តាញផ្លូវថ្នល់ ដើម្បីពង្រីកឱកាសរកប្រាក់ចំណូល និងការទទួលបាននូវសេវាកម្មផ្សេងៗ។ គម្រោងកែលំអផ្លូវជនបទ ចំនួន ៧២៩ គីឡូម៉ែត្រនេះ នឹងផ្តល់នូវផ្លូវដែលមានសុវត្ថិភាព ប្រសិទ្ធភាពចំណាយ និងធន់នឹងការប្រែប្រួលអាកាសធាតុ នៅក្នុងខេត្តចំនួន៩ ដែលមានប្រជាជនក្រីក្រជាច្រើនរស់នៅ"។

ផ្លូវជនបទបានរងការខូចខាតដោយសារតែខ្វះថវិកា ការថែទាំងមិនបានល្អ និងកំណើនការធ្វើចរាចរណ៍។ គម្រោងនេះនឹងជួសជុលកែលំអផ្លូវថ្នល់ដែលខូចខាត អោយមានភាពល្អប្រសើរឡើងវិញ នៅខេត្ត បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ពោធិសាត់ សៀមរាប និងខេត្តតាកែវ។

គម្រោងនេះធ្វើបន្តពីគម្រោងកែលំអផ្លូវជនបទ ទី១ របស់ ADB ដែលបានអនុម័តនៅឆ្នាំ ២០១០ និងកំពុងជួសជុលផ្លូវប្រវែងជាង ៥០០គីឡូម៉ែត្រ ដែលភ្ជាប់មកជាមួយនូវកម្មវិធីបង្កើនការយល់ដឹងពីសុវត្ថិភាពចរាចរ។

ក្រៅពីបន្តធ្វើការកែលំអផ្លូវថ្នល់ គម្រោងដែលមានតម្លៃ ១១៨លានដុល្លារ នេះនឹងបន្តពង្រឹងកិច្ចការគ្រប់គ្រងផ្លូវជនបទ និងធ្វើឲ្យប្រសើរឡើងនូវការរៀបចំផ្សេងៗរបស់ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការថែទាំផ្លូវ។ ដោយសារការដឹកទំនិញលើសទម្ងន់ ជាមូលហេតុដ៏ចម្បងមួយ ដែលនាំឲ្យផ្លូវខូច គម្រោងនេះនឹងពង្រីកកម្មវិធីត្រួតពិនិត្យការដឹកលើសទម្ងន់។

អត្រាគ្រោះថ្នាក់លើដងផ្លូវនៅក្នុងប្រទេសកម្ពុជាបានកើនឡើងគុណនឹង៣ចាប់តាំងពីឆ្នាំ ២០០២ មក។ ដោយសារតែ ផ្លូវល្អអនុញ្ញាតិឲ្យអ្នកបើកបរបង្កើនល្បឿនខ្ពស់ជាងមុន គម្រោងនេះនឹពង្រីកកម្មវិធីសុវត្ថិភាពចរាចរម្ហូលដ្ឋាន បន្តពីគម្រោងមុន។

បន្ថែមពីលើនេះ ការគិតគូរពីការប្រែប្រួលអាកាសធាតុក៏ជាផ្នែកមួយនៃគម្រោងនេះដែរ ដោយហេតុថា ផ្លូវជនបទងាយនឹងរងការខូចខាតដោយសារការប្រែប្រួលអាកាសធាតុ និងទឹកជំនន់។ គម្រោងនេះនឹងរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងគ្រោះអាសន្នតាមសហគមន៍ សម្រាប់ប្រជុំកោះចំនួន ៦ នៃទន្លេមេគង្គ និងកម្មវិធីផែនការបៃតង នៅក្នុងខេត្តទាំង៩ ដែលស្ថិតនៅក្រោមគម្រោង។

កញ្ចប់ថវិកា ១១៨ លានដុល្លារនេះ រួមបញ្ចូលទាំងប្រាក់កម្ចី ៥៤ លានដុល្លារ របស់ ADB សម្រាប់គម្រោងកែលំអផ្លូវជនបទ ទី២ កម្ចី ៩១លានដុល្លាររបស់រដ្ឋាភិបាលនៃសាធារណៈរដ្ឋកូរ៉េ ជំនួយឥតសំណងចំនួន ៦.៦៧ លានដុល្លាររបស់រដ្ឋាភិបាលអូស្រ្តាលី និងជំនួយឥតសំណង ៥.៩លានដុល្លារ របស់មូលនិធិអភិវឌ្ឍន៍ Nordic។ ADB នឹងគ្រប់គ្រងជំនួយឥតសំណងទាំងពីរ។ រដ្ឋាភិបាលកម្ពុជា នឹងផ្តល់ហិរញ្ញប្បទានចំនួន ១១.១៦ លានដុល្លារសម្រាប់គម្រោងនេះ។

មានមូលដ្ឋាននៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រ នៅអាស៊ី និងប៉ាស៊ីហ្វិក តាមរយៈកំណើនសេដ្ឋកិច្ចដើម្បីទាំងអស់គ្នា កំណើនដែលធានានិរន្តរភាពបរិស្ថាន និងសមាហរណកម្មតំបន់។ បង្កើតឡើងនៅក្នុងឆ្នាំ ១៩៦៦ ធនាគារនេះគឺជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ប្រទេស ដែលក្នុងនោះមាន ៤៨ ប្រទេស មកពីតំបន់នេះ។ នៅក្នុងឆ្នាំ ២០១៣ ជំនួយដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ីសរុបមានចំនួន ២១ ពាន់លានដុល្លារ បូករួមទាំងសហប្រទានចំនួន ៦,៦ ពាន់លានដុល្លារផង។

**Media Inquiries:**
**Ayun Sundari**
**Tel: (632) 632 5331**
**Mob: (63) 920 949 6419**
**E-mail: asundari@adb.org**

**Connect with us on Twitter @ADB_HQ**